**ព្រះរាជាណាចក្រ កម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
**សភាផ្នែករដ្ឋប្បវេណី**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ ១២៤
ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៨
**សាលដីកា**
លេខៈ ១៣៧
ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០០

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ ២០០០ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម **ឱត មុន្នី** ជាប្រធាន
២-លោក **ប៉ែន ស៊ុន** ជាចៅក្រម
៣-លោក **ប្រាក់ គីមសាន** ជាចៅក្រម
៤-លោក **ស៊ិន ឌឹម** ជាចៅក្រមរបាយការណ៍
៥-លោក **សោម សិរិវឌ្ឍ** ជាចៅក្រម

**ក្រឡាបញ្ជី**

-លោក **ទឹម សង្ហារិទ្ធិ**

**តំណាងមហាអយ្យការ**

-ឯកឧត្តម **ជួន ស៊ុនឡេង** ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ៧២៤ ចុះថ្ងៃទី០២ ខែ ធ្នូ ឆ្នាំ១៩៩៧ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៤០៩ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ វ៉ាយ ធឿន ភេទស្រី អាយុ៣៧ ឆ្នាំជាតិខ្មែរ មុរបរធ្វើស្រែ ទីលំនៅភូមិល្វេថ្មី ឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ ។ ឪពុកឈ្មោះ ឯម អៀម (ស)ម្តាយឈ្មោះ វ៉ាយ ព្រីង (ស) ប្តីឈ្មោះ នេត អ៊ាល ។

មានមេធាវីអ្នកស្រី ស៊ិន សុវ៉ន

និងចុងបណ្តឹងសាទុក្ខឈ្មោះ នេត សំអាត ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែទីលំនៅភូមិល្វេថ្មី ឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ ។ ឪពុកឈ្មោះ នេត ណុប(ស) ម្តាយឈ្មោះអ៊ំ យី (ស) ប្រពន្ធឈ្មោះ ខាត់ ខាន់ ។

និងតតីយជនឈ្មោះ នូវ និន្ន ភេទប្រុស អាយុ ៥២ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ ទីលំនៅភូមិល្វេថ្មី ឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ ។

**កម្មវត្ថុបណ្តឹង :** ប្តឹងទាមទារដីលំនៅដ្ឋានទំហំ ៦ម x ១១៧ម.

បានឃើញបណ្តឹងសាទុក្ខលេខ៤៦១ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៩៧ របស់អ្នកស្រី វ៉ាយ ធឿន បានប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេច នៃសាលដីកាលេខ៧២៤ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ១២៤ថ្ងៃទី២៧ ខែមេសាឆ្នាំ១៩៩៨ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី០៩-០៨-៩៥ របស់ដើមចោទឈ្មោះ វ៉ាយ ធឿន ប្តឹងសុំឱ្យឈ្មោះ នេត សំអាត ចែកដីទំហំ ៦,៥មx១១៧ម មកឱ្យខ្លួនដោយសំអាងថា នៅឆ្នាំ១៩៨១ ពេលខ្លួនធ្វើមាតុភូមិនិវត្តន៍មក រស់នៅជាមួយម្តាយក្មេកឈ្មោះ អ៊ំ យី និង ប្អូនថ្លៃឈ្មោះនេត សំអាត (ចុងចម្លើយ) មុនពេលម្តាយក្មេក ស្លាប់បានប្រាប់ថា ឱ្យចែកដីនេះ (ដីកើតហេតុ ) ជាពីរចំណែក គឺឱ្យមកខ្លួនមួយចំណែក និង មួយចំណែកទៀតឱ្យទៅ នេត សំអាត ។ ក្រោយពេលបោះឆ្នោតហើយ (ឆ្នាំ៩៣ ) ប្តីខ្លួនក៏ស្លាប់ ហើយនេត សំអាត បានធ្វើ របងព័ទ្ធយកដីនេះទាំងអស់ ។ មុនពេលមានទំនាស់ នេត សំអាត បានបបួលខ្លួនលក់គឺ ចែកគ្នាបានម្នាក់មួយតម្លឹងមាស តែខ្លួនមិនព្រមលក់ ។ ក្រោយមកឈ្មោះអាត បានមកដេញខ្លួនឱ្យរុះផ្ទះចេញពីដីកើតហេតុ ហើយបើមិនរុះទេ ឱ្យមាសទៅគេប្រាំបីជីទៀត ។ ពេលនោះស្រាយនៅឃុំ ឈ្មោះ អាត បានយល់ព្រមប្រគល់ដីចំណែករបស់គាត់ មកឱ្យខ្លួនដោយ ឱ្យខ្លួនប្រគល់មាសប្រាំពីរជីបន្ថែមទៀតគំរប់ប្រាំបីជី ដោយពីមុនមកឈ្មោះ អាត បានយកពីខ្លួនមួយជីហើយ ។ ដោយរកលុយមិនបានខ្លួនក៏ប្រាប់ឈ្មោះអាតឱ្យលក់ដីចំណែករបស់ អាត ទៅតែឈ្មោះអាត លក់ទាំងដីដែលជាចំណែករបស់ខ្លួនទៀតផង ទើបខ្លួនប្តឹងសុំសិទ្ធិគ្រប់គ្រងដីចំណែករបស់ខ្លួន គ្រប់គ្រងជាកម្មសិទ្ធិតទៅ ។

តាមពាក្យបណ្តឹង ចុះថ្ងៃទី ២៦-០១-១៩៩៦ របស់តតិយជនឈ្មោះនាង ហ៊ុន ពៅ(ផ្ទេរសិទ្ធិឱ្យឈ្មោះនូវ និន្ទ) ប្តឹងទាមទារដីលំនៅដ្ឋាន(ដីកើតហេតុ) និងសុំឱ្យនាងវ៉ាយ ធឿន រុះផ្ទះចេញពីដីទំនាស់ ដោយអាងហេតុថា ដីនេះខ្លួនបានទិញពីម្ចាស់ដើមឈ្មោះ នេត សំអាត ដោយមានលិខិតផ្ទេរសិទ្ធិ លក់ដី និងមានសាក្សី ដឹងឮ ត្រឹមត្រូវទៀតផង ។

បានឃើញសាលក្រមលេខ០៦ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៩៧ របស់តុលាការខេត្តតាកែវ សម្រេចចំពោះមុខគូក្តី ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ :

១. ទទួលពាក្យបណ្តឹងចុះថ្ងៃទី០៩-០៨-៩៥ របស់ដើមចោទឈ្មោះ វ៉ាយ ធឿន ទុកជាត្រឹមត្រូវ តាមទម្រង់តែសម្រេចបដិសេធពាក្យបណ្តឹងនេះចោលដោយខុសនឹងគតិច្បាប់ ។

២- ទទួលពាក្យបណ្តឹងតបតតិយជនចុងចម្លើយឈ្មោះហ៊ុន ពៅ ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់។

៣- ទទួលស្គាល់លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី២៦-០១-៩៦ របស់តតិយជនចុងចម្លើយឈ្មោះហ៊ុន ពៅ ឱ្យទៅតំណាងឈ្មោះ នូវ និន្ទ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

៤- ទទួលស្គាល់លិខិតទិញ-លក់ លំនៅដ្ឋាន ចុះថ្ងៃទី០៥-០៩-៩៥ រវាងអ្នកលក់ឈ្មោះនេត សំអាត និង ប្រពន្ធឈ្មោះ ខាត់ ខាន់ និង អ្នកទិញឈ្មោះ សំ ពៅ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

៥- ដីទំនាស់ដែលមាន ជ្រុងខាងជើង និងខាងត្បូងប្រវែង៨៨ម. ជ្រុងខាងកើតប្រវែង ៦,៩០ម ជ្រុងខាងលិចប្រវែង ៦,៨០ម មានព្រំប្រទល់ខាងជើងទល់ដី ណុប ផែន ខាងត្បូងទល់ដីឈ្មោះហ៊ុន ពៅ ខាងកើតទល់ចំណីផ្លូវជាតិលេខ២ ខាងលិចទល់ដីឈ្មោះ ណុប ផែន ដែលស្ថិតនៅក្នុងភូមិល្វេថ្មី ឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ ។ ត្រូវប្រគល់សិទ្ធិឱ្យតតិយជនចុងចម្លើយឈ្មោះ ហ៊ុន ពៅ តំណាងដោយឈ្មោះ នូវ និន្ទ កាន់កាប់និង ប្រើប្រាស់តាមច្បាប់តទៅ ។

៦- បង្គាប់ឱ្យដើមចោទឈ្មោះ វ៉ាយ ធឿន រុះរើលំនៅដ្ឋានចេញពីដីទំនាស់ ក្នុងកំណត់រយៈពេល៣០ថ្ងៃគិតចាប់តាំងពីថ្ងៃផុតបណ្តឹងឧទ្ធរណ៍ ។

៧- សម្រេចរឹបអូសប្រាក់ប្រដាប់ក្តី: ពន្ធហ្នឹង និងពន្ធចុះបញ្ជីក្តី១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ២០០៛ ចំណាយលើការប្រគល់ដីកាកោះចំនួន ៥០០០៛ សរុប ៧០០០៛ ពីដើមចោទឈ្មោះ វ៉ាយ ធឿន ដែលបានបង់ទុករួច ។

កាលបើផុតកំណត់ ប្តឹងឧទ្ធរណ៍ បង្គាប់ឱ្យដើមចោទឈ្មោះ នាង វ៉ាយ ធឿន បង់ពន្ធសមាមាត្រ មួយភាគរយលើតម្លៃដីដែលមានទំនាស់គឺ $\frac{៦៧៥X១}{១០០} = ៦.៧៥០៛$ ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋ ៨០ភាគរយគឺ $\frac{៦៧៥០X៨០}{១០០} = ៥.៤០០៛$ និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស២០ភាគរយគឺ $\frac{៦៧៥០X២០}{១០០} = ១៣៥០៛$ ។

សាលក្រមនេះ ជំនុំជំរះជាសាធារណៈ ចំពោះមុខគូក្តី ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍កំណត់រយៈពេល៦០ថ្ងៃ គិតចាប់តាំងពីថ្ងៃប្រកាសសាលក្រម ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ១០ ចុះថ្ងៃទី០៥ ខែមិនា ឆ្នាំ១៩៩៧ របស់អ្នកស្រី វ៉ាយ ធឿន ដែលប្តឹងជំទាស់នឹងសាលក្រមលេខ០៦ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៩៧ របស់តុលាការខេត្តតាកែវ លើសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៧២៤ ចុះថ្ងៃទី០២ខែធ្នូ ឆ្នាំ ១៩៩៧ របស់សាលា ឧទ្ធរណ៍ ចំពោះមុខគូក្តី ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៥-០៣-៩៧ របស់ឈ្មោះ វ៉ាយ ធឿន ទុកជាត្រឹមត្រូវ តាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២. តម្កល់សាលក្រមរដ្ឋប្បវេណីលេខ០៦ ចុះថ្ងៃទី២០.០២.៩៧ របស់តុលាការខេត្តតាកែវ ទុកជាបានការដដែល ។

៣. កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ ៥.០០០៛ និងអាជ្ញាធរតុលាការ៥.០០០៛ សរុប ១៣០០០៛ ។

៤- សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៤៦១ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៩៧ របស់អ្នកស្រី វ៉ាយ ធឿន បានប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ៧២៤ ចុះថ្ងៃទី ០២ ខែ ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសារណាការពារ ចុះថ្ងៃទី ០៤-០៨-១៩៩៩ របស់អ្នកស្រី វ៉ាយ ធឿន

បានឃើញសារណាតប ចុះថ្ងៃទី២៤-០១-២០០០ របស់លោក នេត សំអាត

បានឃើញសារណាតប ចុះថ្ងៃទី២៤-០១-២០០០ របស់លោក នូវ និន្ន "តតិយជន"

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា

- បណ្តឹងសាទុក្ខរបស់ដើមចោទ ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិចារណា ។

- សាលដីការដ្ឋប្បវេណីលេខ៧២៤ ចុះថ្ងៃទី០២-១២-៩៧ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្ដីមកនេះ មានការខុសឆ្គងទាំងទម្រង់ និងគតិច្បាប់ហើយ ។ អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិចារណាតាមច្បាប់តទៅ ។

បានស្ដាប់ចម្លើយរបស់ឈ្មោះ វ៉ាយ ធឿន ជាដើមចោទ និង ម្ចាស់បណ្ដឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា ក្នុងឆ្នាំ១៩៩១ ខ្លួន ព្រមទាំងក្រុមគ្រួសារ បានធ្វើមាតុភូមិនិវត្តន៍មកកាន់ស្រុកកំណើតវិញ ដោយបានទៅរស់នៅជាមួយម្ដាយក្មេកឈ្មោះអ៊ុំ យី កាលណោះ នៅទូទាំងប្រទេសរដ្ឋាភិបាលបានចេញគោលនយោបាយបែងចែកដីធ្លីជូនប្រជាជនមាតុភូមិនិវត្តន៍ ក្នុងនោះក៏មានគ្រួសារខ្លួនមួយដែរ ។ តែម្ដាយខ្លួន ពុំឱ្យគ្រួសារខ្លួន ចេញទៅណាទេ គាត់សុខចិត្តបែងចែកដីជាកម្មសិទ្ធិរបស់គាត់ ១ចំហៀង ឱ្យខ្លួនធ្វើផ្ទះនៅ និងទុកមួយចំហៀងសម្រាប់ គាត់រស់នៅជាមួយកូនឈ្មោះ នេត សំអាត ដែលស្ថិតនៅក្នុងបន្ទុករបស់គាត់ ។ នៅឆ្នាំ ១៩៩២ ម្ដាយខ្លួនឈឺស្លាប់ ហើយឆ្នាំ១៩៩៣ ប្ដីខ្លួនក៏ស្លាប់ទៀតបានបន្សល់ទុកកូន ៥នាក់ នៅក្នុងបន្ទុក ។ រំលងបាន ២, ៣ ឆ្នាំក្រោយមក ឈ្មោះ នេត សំអាត ជាប្អូនថ្លៃ បានបបួលខ្លួនលក់ដីទាំងអស់នេះចេញ តែដោយខ្លួនមិនព្រមលក់គេក៏លក់ដីជាចំណែក របស់គេមកឱ្យខ្លួនចំនួន ៨ដី ដោយពុំទាន់មានប្រាក់ឱ្យខ្លួនក៏ប្រគល់ជូន ១ដីសិន ចាំរុះរើផ្ទះហើយចាំឱ្យ ៧ដីទៀត តែក្រោយមកឈ្មោះ នេត សំអាត ប្រែក្រឡាស់ពុំព្រមលក់មកឱ្យខ្លួនវិញទេ ហើយថែមទាំងលួចលក់ដីជាចំណែករបស់ខ្លួនទៀត ។ សូមសំណូមពរទាមទារដីចំណែករបស់ខ្លួនវិញ ។

បានស្ដាប់ចម្លើយរបស់ឈ្មោះ នេត សំអាត ជាចុងចម្លើយ និងចុងបណ្ដឹងសាទុក្ខនៅពេលជំនុំជំរះ បានឆ្លើយបញ្ជាក់ថា : ការលើកឡើងរបស់បងស្រីឈ្មោះ វ៉ាយ ធឿន ដែលបានលើកឡើងនេះ គឺបង្កាច់បង្ខូចទាំង ស្រុង ដីនេះខ្លួនបានកាន់កាប់តាំងពីឆ្នាំ១៩៧៩ កាលណោះម្ដាយខ្លួនចាស់ជរាស្ថិតនៅក្នុងបន្ទុករបស់ខ្លួន ឯបងខ្លួនទើប តែមករស់នៅក្នុងឆ្នាំ១៩៩៣ ទេ ខ្លួនពិតជាបានលក់១ចំហៀងឱ្យទៅបងឈ្មោះ វ៉ាយ ធឿន ក្នុងតម្លៃ៨ដី ពិតមែន ដោយកក់១ដី តែដោយគាត់គ្មានប្រាក់ឱ្យគ្រប់ ខ្លួនក៏លក់ដីនេះទៅឱ្យអ្នកផ្សេងវិញ។ខ្លួនសូមបញ្ជាក់ថាដី នេះ គឺខ្លួនបានកាន់កាប់ពីឆ្នាំ១៩៧៩ ប្រាកដមែន ដោយមានរដ្ឋអំណាចទទួលស្គាល់ត្រឹមត្រូវ ។

បានស្ដាប់ចម្លើយរបស់ឈ្មោះ នូវ និន្ទ ជាតតិយជន នៅពេលជំនុំជំរះ បានឆ្លើយបញ្ជាក់ថា : សូមបដិសេធរបាយការណ៍របស់ដើមចោទទាំងស្រុងឈ្មោះនេត សំអាត បានកាន់កាប់ដីនេះតាំងពីឆ្នាំ១៩៧៩ ដោយ មានម្ដាយចាស់ជរានៅក្នុងបន្ទុក ដោយឡែកបងរបស់ នេត សំអាត ទើបធ្វើមាតុភូមិនិវត្តន៍មកស្រុកកំណើត ក៏ទិញដីពី នេត សំអាត ក្នុងតម្លៃ ៨ជីមាស តែទើបតែឱ្យ ១ជី ប៉ុណ្ណោះ ហើយក៏ធ្វើផ្ទះនៅរហូតមក ដោយមានទំហំ៦ម x ១១៧ម ។ ខ្ញុំបាទសូមជំរាប ឯកឧត្ដមថា ក្នុងឆ្នាំ១៩៩១ នេត សំអាត មានកូន២នាក់ រួចទៅ ហើយ ហើយបច្ចុប្បន្នមានដល់ ៧នាក់ ឯណោះ ។ ពេលទិញនេះ ខ្លួនដឹងថាមានទំនាស់រួចទៅហើយ ក៏ប៉ុន្តែ ដោយអាងថា ដីនោះជារបស់ នេត សំអាត ព្រោះខ្លួនក៏ជាអ្នករស់នៅភូមិនេះ តាំងពីឆ្នាំ ១៩៧៩ មកដែរ ។

បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីអ្នកស្រី ស៊ុន ស៊ីរីន បញ្ជាក់ថា: ដីទំនាស់នេះ គឺជាដីកម្មសិទ្ធិរបស់ឈ្មោះ អុំ យី ដែលជាម្ដាយ បានគ្រប់គ្រងតាំងពីឆ្នាំ១៩៧៩ មកម៉្លេះ ដោយគាត់ជាមេគ្រួសារ ។ ឆ្នាំ ១៩៩១ វ៉ាយ ធឿន និង

ក្រុមគ្រួសារ បានធ្វើមាតុភូមិនិវត្តន៍ត្រឡប់មករស់នៅស្រុកកំណើតវិញ ម្តាយឈ្មោះ អ៊ំ យី ស្លាប់ ឈ្មោះ នេត សំអាតក៏ចាប់ផ្តើមរំលោភបំពានលួចយកដីរបស់ វ៉ាយ ធឿនទៅលក់ដែលជាការបំពាន និងអំពើរបស់ម្តាយខ្លួន។

តាមការស្រាវជ្រាវឃើញថា ដីនេះជាកម្មសិទ្ធិរបស់ឈ្មោះអ៊ំ យី ពិតប្រាកដណាស់ ព្រោះឆ្នាំ ១៩៧៩ ឈ្មោះ នេត សំអាត នៅជាអនីតិជននៅឡើយ យោងតាមច្បាប់ភូមិបាលមាត្រា១៧០ ចែងថា សន្តតិកម្ម គឺជាការផ្ទេរនូវបេតិកភ័ណ្ឌនៃបុគ្គលណាម្នាក់ឱ្យទៅជនម្នាក់ទៀត ឬ ច្រើនអ្នកហៅថាទាយាទ ។ ក្នុងនាមមេធាវីការពារក្តី នាងខ្ញុំសូមសំណូមពរ សុំបដិសេធសាលដីការបស់សាលាឧទ្ធរណ៍ចោលជាអសារបង់ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោះសារបស់គូភាគី របស់តតិយជន និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៤៦១ ចុះថ្ងៃទី០២-១២.៩៧ របស់អ្នកស្រី វ៉ាយ ធឿន ស្ថិតនៅក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការណ៍ដែលសាលាឧទ្ធរណ៍ ក៏ដូចតុលាការខេត្តតាកែវ ដែលយល់ឃើញថា លោក នេត សំអាត បានកាន់កាប់ដីទំនាស់តាំងពីឆ្នាំ១៩៧៩ ដោយអាងហេតុថា អ្នកស្រី អ៊ំ យី ជាម្តាយរស់នៅក្នុងបន្ទុករបស់លោក នេត សំអាត នោះ គឺជាការភ័ន្តច្រឡំ ពីព្រោះថា តាមប័ណ្ណគ្រួសារលេខ៥៨ សៀវភៅលេខ IV ចុះថ្ងៃទី១១-១១-៨៦ លោក នេត សំអាត កើតនៅឆ្នាំ១៩៧០ ដូច្នេះលោក នេត សំអាត មានអាយុទើបតែ០៩ឆ្នាំ ដែលពុំអាចមានសិទ្ធិទទួលរបបដីធ្លីបានឡើយ ។

-យល់ឃើញថា ក្នុងកំណត់ហេតុដោះស្រាយទំនាស់ ចុះថ្ងៃទី១៩-១០-៩៤ (ឯ.១៣/៦) របស់សាលាឃុំ ៨មុំ ក៏ដូចកំណត់ហេតុផ្សះផ្សា ចុះថ្ងៃទី១២-០៨-៩៥ របស់តុលាការខេត្តតាកែវដែរ ចុងចម្លើយសុទ្ធតែទទួលស្គាល់ថា ដីទំនាស់ត្រូវម្តាយខ្លួនចែកឱ្យដើមចោទរួចហើយ ។

-យល់ឃើញថា ចុងចម្លើយយកដីបណ្តាំសន្តតិកម្មធន្ទះរបស់ម្តាយទៅលក់ឱ្យជនដទៃ ជាការបំពាននឹងមាត្រា១៧០ នៃច្បាប់ភូមិបាល ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៧២៤ ចុះថ្ងៃទី ០២-១២-៩៧ របស់សាលាឧទ្ធរណ៍ ដែលសម្រេចសេចក្តីមកនេះ មានការខុសឆ្គង ទាំងទម្រង់ ទាំងគតិច្បាប់ ។

## **ហេតុដូច្នេះ**

វិនិច្ឆ័យសេចក្តីចំពោះមុខគូក្តី

១- ទទួលបណ្តឹងសាទុក្ខលេខ៤៦១ចុះថ្ងៃទី០២-១២-៩៧ របស់អ្នកស្រី វ៉ាយ ធឿន ទុកជា ត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- ទុកជាមោឃៈ សាលដីការដ្ឋប្បវេណីលេខ៧២៤ ចុះថ្ងៃទី០២-១២-៩៧ របស់សាលាឧទ្ធរណ៍ ទាំងមូល ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ១២៤ ចុះថ្ងៃទី២៧-០៤-៩៨ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះ ជាថ្មីឡើងវិញ ។

៤. រឹបអូសប្រាក់ប្រដាប់ក្តី ដែលដើមចោទបានបង់ទុកនៅតុលាការកំពូលចំនួន១៩.០០០រៀល គឺ

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀលសម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយក្នុងការប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ហើយតម្រូវឱ្យចុងចម្លើយ សងប្រាក់ចំនួន១៩.០០០រៀល នេះ ទៅឱ្យដើមចោទវិញ ។

៥. សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០០ ។